# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជារាត្រីបុណ្យចម្លងនៅព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង
# តាកែវ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០
# នៅក្នុងភាពងងឹតយើងបានឃើញព្រះពន្លឺ

**អត្ថបទទី១៖ កំណើតពិភពលោក ១,១-២,២**

ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «ចូរមានពន្លឺ!» ពន្លឺក៏កើតមានឡើង។ កណ ១,៣

**អត្ថបទទី២៖ សេរីភាព ១៤,១៥-១៥,១**

ចូរលើកដំបងរបស់អ្នកឡើង ហើយលើកដៃតម្រង់ទៅសមុទ្រ រួចវាយទឹកសមុទ្រឲ្យញែកចេញពីគ្នា ដើម្បីឲ្យកូនចៅអ៊ីស្រាអែលដើរតាមបាតសមុទ្រ។ សរ ១៤,១៦

**អត្ថបទទី៣៖ អេសាយ ៥៥,៥-១៤**

ចូរស្វែងរកព្រះអម្ចាស់ ក្នុងពេលដែលព្រះអង្គសព្វព្រះហឫទ័យ ឲ្យអ្នករាល់គ្នារកព្រះអង្គឃើញ ចូរអង្វររកព្រះអង្គ ក្នុងពេលដែលទ្រង់គង់នៅជិតអ្នករាល់គ្នា។ អស ៥៥,៦

**អត្ថបទទី៤៖ រ៉ូម ៦,៣-១១**

ប្រសិនបើយើងរួមស្លាប់ជាមួយព្រះគ្រីស្ត យើងក៏ជឿថា យើងនឹងមានជីវិតរួមជាមួយព្រះអង្គដែរ។ រម ៦,៨

**ដំណឹងល្អ៖ ម៉ាថាយ ២៨,១-១០**

ទេវទូតនិយាយទៅកាន់ស្ត្រីៗថា៖ កុំភ័យខ្លាចអ្វី! ខ្ញុំដឹងថានាងៗមករកព្រះយេស៊ូ ជាអ្នកភូមិណាសារ៉ែតដែលគេបានឆ្កាង។ មថ ២៨,៥

បងប្អូនជាទីស្រឡាញ់!

**ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ា អាលេលូយ៉ា!**

នៅក្នុងភាពងងឹតនេះ យើងបានឃើញពន្លឺដែលបំភ្លឺពិភពលោករបស់យើង ពន្លឺរបស់ព្រះគ្រីស្តដែលយាងមកដើម្បីណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី។ ព្រឹកឡើង ពេលស្ត្រីៗធ្វើដំណើរទៅផ្នូររបស់ព្រះយេស៊ូគេបានជួបជាមួយទេវទូត ទេវទូតនោះបានប្រាប់ទៅនាងៗថា "**កុំភ័យ កុំខ្លាចអ្វី**"។ ពេលស្ត្រីត្រឡប់ទៅទីក្រុងយេរូសាឡឹម ដើម្បីទៅប្រាប់ដំណឹងដល់ក្រុមគ្រីស្តទូតថា "**ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ**" គេបានជួបជាមួយព្រះយេស៊ូផ្ទាល់។ នៅពេលនោះព្រះយេស៊ូមានព្រះបន្ទូលដល់នាងៗថា "**កុំភ័យ កុំខ្លាចអ្វីឡើយ សូមទៅប្រាប់បងប្អូនខ្ញុំឲ្យគេទៅស្រុកកាលីឡេចុះ គេនឹងឃើញខ្ញុំនៅទីនោះ**" គឺគេនឹងឃើញព្រះយេស៊ូផ្ទាល់។

បងប្អូនជាទីស្រឡាញ់ៗ

នៅក្នុងភាពងងឹត ពន្លឺរបស់ព្រះគ្រីស្តបានភ្លឺយ៉ាងត្រចះត្រចង់ ដោយសារនៅពេលហ្នឹងព្រះយេស៊ូបានឈ្នះសេចក្តី។ យប់នេះ យើងមានអារម្មណ៍ថាយើងឯកោ ដោយសារយើងនៅតាមផ្ទះនីមួយៗដែលខិតខំអធិដ្ឋានផ្ទាល់ខ្លួន។ ជួនកាលយើងនៅម្នាក់ឯងក្នុងផ្ទះ ជួនកាលបូជាចារ្យនៅជាមួយគ្រីស្តបរិស័ទម្នាក់ឬពីរនាក់ ដើម្បីស្របតាមច្បាប់ (គ្មានសិទ្ធិជួបជុំគ្នាបែបសាសនា) យប់នេះខ្ញុំនៅជាមួយតែប្រាំមួយនាក់ ដែលរាល់ឆ្នាំយើងធ្លាប់មានរាប់រយនាក់នៅរាត្រីបុណ្យចម្លង។

យប់នេះ ខ្ញុំសូមអធិដ្ឋានសម្រាប់បងប្អូនរបស់យើង៧០នាក់ ដែលបានត្រៀមទទួលពិធីជ្រមុជទឹកនៅក្នុងយប់នេះ ដោយដឹងថាគេមិនអាចទទួលបានទេ។ ខ្ញុំចង់និយាយដល់បងប្អូនដែលបានត្រៀមខ្លួនអស់ពីសមត្ថភាពថា សូមថែរក្សាជំនឿថ្មីៗដ៏រឹងមាំ សូមបន្តអធិដ្ឋានដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់ ដើម្បីស្គាល់ក្លិនរបស់ព្រះជាម្ចាស់នៅក្នុងដួងចិត្តផ្ទាល់ខ្លួន។ ខ្ញុំអធិដ្ឋានសម្រាប់បងប្អូន៧០នាក់ ដោយសង្ឃឹមថានៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០ ខាងមុខនេះ ជាថ្ងៃដែលយើងគោរពព្រះវិញ្ញាណដ៏វិសុទ្ធយាងមក យើងអាចធ្វើពិធីជ្រមុជទឹកនៅក្នុងព្រះសហគមន៍របស់យើងគ្រប់ទីកន្លែងក្នុងអំណរសប្បាយនៃព្រះវិញ្ញាណដ៏វិសុទ្ធ ប៉ុន្តែនេះអាស្រ័យលើកាលៈទេសៈនិងបរិយាកាសខាងមុខនេះ។

យប់នេះ ខ្ញុំសូមអធិដ្ឋានសម្រាប់លោកឪពុកទាំងអស់នៅក្នុងភូមិភាគភ្នំពេញ ខ្ញុំដឹងថាដូចលោកឪពុកនៃព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា និងលោកឪពុកទាំងអស់នៅក្នុងពិភពលោកទាំងមូល យប់នេះលោកឪពុកថ្វាយអភិបូជាម្នាក់ឯង។ ប៉ុន្តែ តាមពិតព្រះយេស៊ូសោយព្រះទិវង្គតលើព្រះឈើឆ្កាងប្រហែលជិតនៅម្នាក់ឯងដែរ នៅសល់តែព្រះនាងម៉ារីដែលជាម្តាយរបស់ព្រះអង្គនិងសាវ័កដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។ នៅពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញយើងដឹងថានៅពេលនោះព្រះយេស៊ូនៅតែម្នាក់ឯងពិតមែន។ ដូច្នេះ លោកឪពុកជាទីស្រឡាញ់គ្រប់អភិបូជាដែលលោកឪពុកបានថ្វាយជារៀងរាល់ថ្ងៃ ខ្ញុំជឿថាបានណែនាំឲ្យមានផ្លែយ៉ាងច្រើនសម្រាប់លោកឪពុកផ្ទាល់ និងសម្រាប់ព្រះសហគមន៍របស់យើង នៅក្នុងភាពស្ងៀមស្ងាត់នៃការអធិដ្ឋានរបស់លោកឪពុក។ សូមបន្តយកពេលវេលា ដើម្បីភ្ជាប់នៅក្នុងមិត្តភាពយ៉ាងពិសេសជាមួយព្រះជាម្ចាស់ដែលជាព្រះបិតារបស់យើង។ ពិតមែន នៅពេលហ្នឹងយើងជាលោកអភិបាលយើងជាលោកឪពុក រួមជាមួយគ្រីស្តបរិស័ទរបស់យើង យើងមានបទពិសោធថ្មីដោយភ្ជាប់គ្នាយ៉ាងជិតស្និទ្ធបំផុតតាមផ្លូវវិញ្ញាណ។ នេះជាកម្លាំងមួយ សម្រាប់ជីវិតរបស់យើងជាបូជាចារ្យ និង

ជឿថានៅក្នុងពេលវេលានេះដូចជាដួងចិត្តរបស់យើងទៅជាដួងចិត្តថ្មី ដែលស្របតាមព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

យប់នេះ ខ្ញុំសូមអធិដ្ឋានសម្រាប់និស្សិតទេវវិទ្យាល័យ សម្រាប់បងប្រុសបងស្រី បព្វជិតបព្វជីតា សម្រាប់បងប្អូនទាំងអស់ជាអ្នកស្ម័គ្រចិត្តដែលមកពីប្រទេសនានា។ នៅពេលនេះ ខ្ញុំចង់និយាយថា សូមទៅជាស្ត្រីៗដែលទៅផ្នូររបស់ព្រះយេស៊ូមុនគេបង្អស់ សូមទៅជាលោកសិលានិងលោកយ៉ូហានដែលបានចូលទៅក្នុងផ្នូររបស់ព្រះយេស៊ូមុនគេបង្អស់ និងសូមស្តាប់ដំណឹងល្អពីទេវទូតដែលថា "**ឥឡូវនេះព្រះជាម្ចាស់បានជ្រើសរើសបងប្រុសបងស្រី ដើម្បីទៅប្រកាសដំណឹងល្អហ្នឹងដល់បងប្អូនឯទៀតៗរបស់យើង**"។ សូមបើកភ្នែកដើម្បីមើលផ្នូរទទេ និងសូមចូលដូចលោកយ៉ូហាននៅក្នុងផ្នូរនេះ លោកយ៉ូហានបានមើលឃើញនិងបានជឿ ដូច្នេះឲ្យយើងជឿដូចគ្នា។ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ជាខ្លាំង សម្រាប់បងប្រុសបងស្រី បព្វជិតបព្វជីតា អ្នកស្ម័គ្រចិត្តទាំងអស់ ដែលបានអធិដ្ឋានយ៉ាងច្រើនកន្លងមក។ នៅកន្លែងខ្លះ ខ្ញុំដឹងថាមានបងស្រីបានអធិដ្ឋាន៨ម៉ោងក្នុងមួយថ្ងៃ នៅគ្រប់ទីកន្លែងមានការអធិដ្ឋានផ្គាំ ផ្លូវឈើឆ្កាង ធ្វើឲ្យខ្ញុំមានអារម្មណ៍ថានៅក្នុងពេលវេលានេះជាពេលវេលាប្លែក ដូចជានៅក្នុងភូមិភាគភ្នំពេញយើង យើងមានការអធិដ្ឋាន ការធ្វើដំណើរនៅក្នុងផ្លូវវិញ្ញាណអស្ចារ្យមែនទែនដែលយើងឥតដែលមានទេ។ ខ្ញុំជឿថា ព្រះជាម្ចាស់ស្តាប់សម្លេងទូលអង្វររបស់យើង និងព្រះជាម្ចាស់ឆ្លើយតបសម្លេងទូលអង្វររបស់យើង ដោយសារព្រះជាម្ចាស់អាចធ្វើអ្វីៗទាំងអស់បាន។ បងប្រុសបងស្រី បព្វជិតបព្វជីតា និស្សិតទេវវិទ្យាល័យ និងអ្នកស្ម័គ្រចិត្តជាទីស្រឡាញ់ សូមបន្តភ្ញាក់ស្មារតី អធិដ្ឋានហើយអធិដ្ឋានទៀត សម្រាប់ពិភពលោក សម្រាប់ប្រទេសកម្ពុជា សម្រាប់ព្រះសហគមន៍របស់យើង។

យប់នេះ ខ្ញុំសូមអធិដ្ឋានសម្រាប់គ្រីស្តបរិស័ទយើងទាំងអស់នៅក្នុងភូមិភាគភ្នំពេញ សម្រាប់ក្រុមគ្រួសារកាតូលិកក្តី សម្រាប់បងប្អូនដែលមានតែម្នាក់ជាគ្រីស្តបរិស័ទនៅក្នុងក្រុមគ្រួសារក្តី សម្រាប់យុវជនយុវនារីដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ សម្រាប់មនុស្សប៉ុន្មាននាក់ដែលពីមួយថ្ងៃទៅមួយថ្ងៃចូលរួមការអធិដ្ឋានជាមួយយើង តាមហ្វេសបុក តាមយូធូប តាមសៀវភៅដែលយើងបានរៀបចំ តាមរបៀបដែលយើងអាចធ្វើបាន។ ប៉ុន្មានថ្ងៃនេះ ខ្ញុំបានរំភើបមែនទែននៅពេលខ្ញុំបានទទួលរូបថតដែលគេផ្ញើមកខ្ញុំ មានកូន មានឪពុកម្តាយ មានលោកយាយលោកតា នៅតាមផ្ទះកំពុងអធិដ្ឋាន មើលឈើឆ្កាងដោយមានចិត្តស្មោះជាមួយព្រះជាម្ចាស់ ទោះបីមិនអាចចូលព្រះវិហារ។ យើងបានឃើញគ្រួសារជួបជុំគ្នានៅមុខកុំព្យូទ័រ នៅមុខទូរស័ព្ទដៃ ដើម្បីអធិដ្ឋានអស់ពីសមត្ថភាព។ មានគ្រួសារខ្លះគ្មានសមត្ថភាពជួបជុំតាមហ្វេសបុកឬតាមយូធូប គេបានយកសៀវភៅដែលយើងរៀបចំ គេបានខិតខំអធិដ្ឋានជាមួយបងប្អូននៅក្នុង

ក្រុមគ្រួសារ។ ខ្ញុំបានឃើញនៅជុំវិញព្រះវិហារយើង ពីមួយថ្ងៃទៅមួយថ្ងៃបងប្អូនបានជិះកង់មកមើលព្រះវិហារដោយសារគេនឹក ខ្ញុំដឹងថាជារៀងរាល់ថ្ងៃមានបងប្អូនរាប់ពាន់នាក់ដែលបានមើលយើងតាមហ្វេសបុក និងតាមយូធូប។

ពិតមែន បងប្អូនជាទីស្រឡាញ់បទពិសោធថ្មីនេះ ណែនាំឲ្យយើងយល់ថាយើងជាក្រុមគ្រួសារតែមួយនៅក្នុងព្រះយេស៊ូគ្រីស្ត។ ទោះបីយើងនៅម្នាក់ឯង ប៉ុន្តែយើងយល់ថាទំនាក់ទំនងជាមួយព្រះជាម្ចាស់ ទំនាក់ទំនងរវាងគ្នានឹងគ្នានៅក្នុងការអធិដ្ឋាន ជារបៀបថ្មីដែលណែនាំឲ្យយើងជិតស្និទ្ធជាមួយគ្នាទៅវិញទៅមក។

យើងមានប៉ុន្មានសប្តាហ៍ទៀតនៅក្នុងរបៀបនេះ ប៉ុន្តែឲ្យយើងមានសេចក្តីក្លាហាន ឲ្យជំនឿរបស់យើងដែលជាអំណោយទានដ៏ពិសេសដែលយើងបានទទួលពីព្រះជាម្ចាស់ ជម្រុញយើងឲ្យយើងមានកម្លាំងដើម្បីតស៊ូ។

យប់នេះយើងដឹងថា សេចក្តីស្លាប់មិនមែនជាពាក្យចុងក្រោយគឺជីវិតដែលត្រូវតែឈ្នះជានិច្ច។ បន្តិចទៀតខ្ញុំនឹងប្រសិទ្ធីព្រះពរលើទឹកដែលជាទឹកពិសេស ដើម្បីប្រទានព្រះពរដល់បងប្អូនទាំងអស់ ទឹកដែលថែរក្សាបងប្អូនទាំងអស់។

ដូច្នេះ សូមបងប្អូនភ្ញាក់ស្មារតី សូមបើកភ្នែកនៅក្នុងការអធិដ្ឋាន និងសូមមើលស្ថានភាពជុំវិញយើង ស្ថានភាពប្រហែលចាប់ផ្តើមពិបាកសម្រាប់គ្រួសារមួយចំនួនដែលអស់ការងារធ្វើ ដែលគ្មានចំណូល។ ខ្ញុំគិតថា សម្រាប់យើងដែលជាព្រះសហគមន៍កាតូលិក យើងត្រូវការត្រៀមខ្លួនដើម្បីលើកទឹកចិត្ត ដើម្បីជួយ ដើម្បីជម្រុញ ដើម្បីណែនាំឲ្យស្ត្រីមេម៉ាយ កុមារកំព្រា ជនបរទេស និងអ្នកដែលអស់សង្ឃឹមនៅក្នុងជីវិត ឲ្យគេរកឃើញពន្លឺរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់គេផ្ទាល់។ យើងដឹងថា នៅជុំវិញយើងមានបងប្អូនក្រីក្រដែលមានទុក្ខលំបាក ដូច្នេះសូមគ្រីស្តបរិស័ទម្នាក់ៗបើកភ្នែកមើលអ្នកជិតខាងផ្ទាល់ខ្លួន។ សម្រាប់ក្រុមមេត្តាករុណានីមួយៗដែលយើងមាននៅតាមព្រះសហគមន៍ សូមបើកភ្នែកនិងបើកដៃដើម្បីជួយលើកទឹកចិត្តនិងធ្វើដំណើរជាមួយបងប្អូនដែលមានទុក្ខលំបាក។

នៅពេលនេះ ខ្ញុំសូមឲ្យសម្ព័ន្ធកាតូលិកសម្រាប់មេត្តាករុណានិងអភិវឌ្ឍ ការិយាល័យភូមិភាគទាំងអស់ សូមភ្ញាក់និងត្រៀមខ្លួនដើម្បីលើកទឹកចិត្ត ដើម្បីធ្វើដំណើរជាមួយបងប្អូនដែលកំពុងមានទុក្ខលំបាក។

**ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ**

ព្រះហឫទ័យរបស់ព្រះគ្រីស្ដជម្រុញយើងឲ្យយើងប្រកាសដំណឹងល្អ ដោយសារយើងដឹងថា យប់នេះព្រះយេស៊ូមានជីវិតថ្មី យប់នេះព្រះយេស៊ូណែនាំឲ្យយើងទាំងអស់ដែលជាគ្រីស្តបរិស័ទជាព្រះសហាគមន៍រស់នៅដូចព្រះយេស៊ូ ស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នា បម្រើគ្នាទៅវិញទៅមកដូចខ្ញុំបានបម្រើអ្នករាល់គ្នា ស្រឡាញ់នៅក្នុងសេចក្តីពិត ស្រឡាញ់នៅក្នុងភាពសកម្មដ៏ពិសេស។

**អាលេលូយ៉ាង អាលេលូយ៉ាង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ាង អាលេលូយ៉ា!**